01676519

លេខ / N°: D273

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Sept-2021, 09:25
CMS/CFO: Sann Rada

**សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អវតក-កសចស**

| | |
|---|---|
| ចំពោះមុខ៖ | សហចៅក្រមស៊ើបអង្កេត |
| កាលបរិច្ឆេទ៖ | ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០២១ |
| ភាសា៖ | ខ្មែរ និងអង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

---

# ដីកាបង្គាប់ឲ្យដាក់សេចក្ដីសន្និដ្ឋានស្ដីពីយុត្តាធិការដែលនៅសេសសល់ ដើម្បីបញ្ចប់សំណុំរឿង ០០៣

---

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Brenda J. HOLLIS

**មេធាវីការពារក្ដី**
អាង ឧត្ដម
Michael G. KARNAVAS

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី**

ហុង គឹមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីណា
វ៉េន ពៅ

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

១. កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះ (“អបជ”) បានចេញសេចក្តីសម្រេចរួមគ្នាជាឯកច្ឆ័ន្ទ (“សេចក្តីសម្រេច”) លើសំណើ (“សំណើ”) របស់សហព្រះរាជអាជ្ញាអន្តរជាតិ (“សពអ”) និងមេធាវីការពារក្តី មាស មុត (“មេធាវីការពារក្តី”) ដែលនៅក្នុងសេចក្តីសម្រេចនោះបានប្រកាសមិនទទួលយកសំណើខាងលើនោះ ដោយហេតុថា អបជ បានសម្រេចរួចហើយលើបញ្ហានានាដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ (“សេចក្តីពិចារណា”)។

២. អបជ បានប្រកាសយ៉ាងច្បាស់ និងជាឯកច្ឆ័ន្ទ នៅក្នុងកថាខណ្ឌ ៧៧ នៃសេចក្តីសម្រេចថា ខ្លួនពុំអាចរកសម្លេងភាគច្រើនលើសលប់នៅក្នុងសេចក្តីពិចារណាស្តីពីបញ្ហាទាំងឡាយ ដែលបានលើកឡើងម្តងទៀតនៅក្នុងសំណើនោះទេ។ ហេតុដូច្នេះ ទឡ្ហីករណ៍ណាមួយ ដែលចៅក្រមទាំងប្រាំបានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (“សចសអ”) ត្រូវទុកជាអសារឥតការ យោងតាមពាក្យពេចន៍ផ្ទាល់របស់ អបជ។

៣. អបជ ក៏បានពន្យល់ផងដែរថា ការគ្រាន់តែចេញសេចក្តីពិចារណាដែលបង្ហាញពីការយល់ឃើញផ្ទាល់របស់ចៅក្រមនីមួយៗ បានន័យថា អបជ បានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ដូច្នេះ អបជ ពុំត្រូវបានតម្រូវឲ្យចេញសេចក្តីសម្រេចរួមគ្នានោះទេ (កថាខណ្ឌ ៦៩-៧៧)។

៤. ចំណុចនេះផ្ទុយទៅនឹងការសម្រេចយ៉ាងច្បាស់របស់អង្គជំនុំជម្រះតុលាការកំពូល (“អជតក”) នៅក្នុងសំណុំរឿង ០០៤/២។

៥. យើងបានជូនដំណឹងដល់ភាគីក្នុងកថាខណ្ឌ ៤២ នៃសេចក្តីសម្រេចរបស់យើងចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ រួចហើយ ដោយបានបញ្ជាក់ថា ប្រសិនបើគ្មានអង្គជំនុំជម្រះផ្សេងទៀតនៅក្នុងតុលាការនេះព្រមទទួលការងារនេះដើម្បីបញ្ចប់សំណុំរឿងទេនោះ យើងនឹងសម្រេចស្នើសុំភាគីដាក់សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង។

៦. ពេលវេលាពេលនេះបានមកដល់ហើយ។ បច្ចុប្បន្ន សំណុំរឿងស្ថិតនៅចំពោះមុខ អបជ ចំនួនពីរលើកហើយបញ្ហាច្បាប់ពាក់ព័ន្ធទាំងអស់ត្រូវបានជជែកលម្អិតដោយភាគីរួចរាល់អស់ហើយ។ យើងពុំឃើញមានទិដ្ឋភាពថ្មីណាមួយទំនងនឹងលេចចេញនោះទេ។ បញ្ហាតែមួយគត់ដែលនៅសល់ដើម្បីកំណត់នោះគឺថា តើយើងមានយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿងនេះដែរឬអត់។

៧. ទោះបីជាយ៉ាងណាក៏ដោយ នៅតែមានលទ្ធភាពដែលថា សពអ អាចមានបំណងប្តឹងទៅ អជតក ស្នើសុំបញ្ចប់រឿងក្តីដូចក្នុងសំណុំរឿង ០០៤/២។

**យោងតាមសំអាងហេតុទាំងនេះ យើង**[1]

- **ស្នើសុំ សពអ ប្រកាស ក្នុងរយៈពេលមួយសប្តាហ៍គិតចាប់ពីថ្ងៃជូនដំណឹងនៃដីកានេះថា តើខ្លួនមានបំណងចង់ប្តឹង អជតក លើករណីនេះដែរឬទេ ហើយប្រសិនបើមិនមាននោះទេ**

- **បង្គាប់ ឲ្យភាគីដាក់មតិយោបល់ដែលខ្លួនអាចមាន អំពីបញ្ហាតែមួយគត់នៃយុត្តាធិការក្នុងរយៈពេលបីសប្តាហ៍គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកានេះ។**

- **បង្គាប់ថា សេចក្តីសន្និដ្ឋាន ដែលពុំលើសពី ១៥ ទំព័រ ជាភាសាអង់គ្លេស ត្រូវដាក់ជាភាសាអង់គ្លេស និងជាភាសាខ្មែរក្នុងពេលដំណាលគ្នា ដោយមិនអនុញ្ញាតឱ្យពន្យារពេល ឬដាក់តែមួយភាសានោះឡើយ។**

- **បង្គាប់ថា គ្មានចម្លើយតប និងការឆ្លើយតបណាមួយនឹងត្រូវបានអនុញ្ញាតឲ្យធ្វើឡើងនោះទេ។**

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០២១

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges
Co-juges d’instruction

**យូ ប៊ុនឡេង** Michael Bohlander

[1] ទោះបីជា សចស ចេញដីកានេះរួមគ្នាក៏ដោយ សចសជ កត់សម្គាល់នៅក្នុងកំណត់ហេតុថា ឯកសារដែលដាក់នៅក្នុងសំណុំរឿងគួរត្រូវបានកំណត់លេខតាមលំដាប់លំដោយ គិតចាប់ពីឯកសារចុងក្រោយដែលត្រូវបានដាក់មុនពេលចៅក្រម Siegfried Blunk លាលែងពីតំណែង ដោយមិនរាប់បញ្ចូលដីកាបង្គាប់ និងសេចក្តីសម្រេចនានា ដែលចេញដោយ សចសបម្រុង Laurent Kasper-Ansermet នោះឡើយ។